# ពិធីបើកយុទ្ធនាការចែកមុងជ្រលក់ថ្នាំ ទូទាំងប្រទេស ចំនួន ២លាន៧សែន ជំហ៊ានទី២ ជូនដល់ប្រជាពលរដ្ឋគោលដៅ និងទិវាផ្តល់ថ្នាំបង្ការដល់កុមារ និងស្ត្រីងាយរងគ្រោះ

ភូមិបិទផ្កា ឃុំស្វាយលើ ស្រុកស្វាយលើ ខេត្ត សៀមរាប

ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១២

**សៀមរាបៈ** កាលពី ព្រឹក ថ្ងៃ ០៦ ខែ កុម្ភះ ឆ្នាំ ២០១២ នៅ ឃុំស្វាយលើ ស្រុកស្វាយលើ ខេត្ត សៀមរាប ខេត្ត សៀមរាប ក្រសួងសុខាភិបាល ក្រោមអធិបតីភាព ឯកឧត្តម **វេជ្ជបណ្ឌិត ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល រួមដំណើរជាមួយថ្នាក់ដឹកនាំមជ្ឈមណ្ឌលជាតិប្រយុទ្ធនិងជំងឺគ្រុនចាញ់ ក្នុងក្របខណ្ឌនៃការអនុវត្តន៍ **ផែនការយុទ្ធសាស្ត្រជាតិលុបបំបាត់ជំងឺគ្រុនចាញ់ ឆ្នាំ២០១១-២០២៥** របស់រាជរដ្ឋាភិបាល ដែលត្រូវបានរៀបចំឡើងតាមការផ្តួចផ្តើមដោយផ្ទាល់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្រសួងសុខាភិបាលកំពុងធ្វើយុទ្ធនាការចែកមុងនេះ ជាយុទ្ធនាការដ៏ធំមួយដែលមិនធ្លាប់មានក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក ក៏ដូចជាក្នុប្រទេសកម្ពុជាដែរ ដោយក្រសួងត្រូវចំណាយអស់ថវិកាប្រមាណ ១៤.៤ លានដុល្លារអាមេរិក (ដប់បួនលាន ៤សែន) ក្នុងនោះ ថវិកាចំនួន ១២.៤ លានដុល្លារអាមេរិក (ដប់ពីរលាន បួនសែន) បានមកពីគំរោងមូលនិធិសកល ដែលគ្រប់គ្រងផ្ទាល់ដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ បាណកសាស្ត្រ និងថវិកាចំនួន ២លានដុល្លារអាមេរិក (ពីរលាន) ទៀតជាថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា សំរាប់បង់ពន្ធនាំចូល។

យុទ្ធនាការនេះមានរយៈកាល ៤ខែ ពីខែ វិច្ឆិកាឆ្នាំ ២០១១ ដល់ខែកុម្ភៈ ឆ្នាំ២០១២ ដើម្បី ប្រគល់ដោយឥតគិតថ្លៃជូនប្រជាជននូវមុង ចំនួន ២,៧ លាន ដែលជាមុងជ្រលក់ថ្នាំមានប្រសិទ្ធភាព៣ឆ្នាំ ជូនប្រជាជន ៨១២ពាន់គ្រួសារ (ជាង៣លាននាក់) នៅ ៤០៥៧ភូមិ (បួនពាន់ ហាសិបប្រាំពីរ) ក្នុងទូទាំងប្រទេសដែលមានហានិភ័យគ្រុនចាញ់នៅ ២០ ខេត្ត។ ជាគោលការណ៍ប្រជាជន ១នាក់ ត្រូវទទួលមុង១ លើកលែងអ្នកដែលបានទទួលរួចហើយក្នុងកំឡុងពេលតិចជាង ៣ ឆ្នាំកន្លងមក។ កាលវិភាគប្រគល់មុងដល់ដៃប្រជាជនត្រូវធ្វើជាពីរជំហ៊ានគឺៈ

**ជំហ៊ានទី១** បានចាប់ផ្តើមពីសប្តាហ៍ទី១ ខែ វិច្ឆិកា ហើយចប់ដោយជោគជ័យ ថ្ងៃទី ៣០ ខែដដែល សំរាប់ខេត្តកំពង់ចាម ស្ទឹងត្រែង កំពង់ធំ កំពង់ឆ្នាំង ខេត្តកែប និងចែកជានិមិត្តរូបសំរាប់ ១០ភូមិ នៅឃុំដំរីផុង ស្រុកឆ្លូង ខេត្តក្រចេះ ដែលខ្ញុំបានទៅចូលរួមដោយផ្ទាល់កាលពីថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១១។ ក្នុងជំហ៊ានទី១ យើងបានដឹកជញ្ជូនមុងចំនួនជាង ៧៨០.០០០មុង (ប្រាំពីរសែន ប្រាំបីម៉ឺន) ទៅកាន់ខេត្តខាងលើក្នុងនោះមុង ៨៦% ត្រូវបានប្រគល់ជូនប្រជាជនដែលមានទីលំនៅអចិន្ត្រៃយ៍ក្នុងភូមិដែលមានហានិភ័យគ្រុនចាញ់ ហើយនៅសល់ ១៤% ទៀតត្រូវបានរក្សារទុកក្នុងឃ្លាំងការិយាល័យសុខាភិបាលស្រុក ឬតាមមណ្ឌលសុខភាពសំរាប់ចែកជូនជាប្រក្រតីបន្តទៀត ដល់ជនចំណាកស្រុកទៅរកការងារធ្វើនៅតំបន់ទាំងនោះ។ ជោគជ័យដែលយើងទទួល

បានក្នុងជំហានទី១ កើតឡើងដោយសារមានការសហការយ៉ាងល្អរវាងក្រុមការងារ ពិសេសលុបបំបាត់ជំងឺគ្រុនចាញ់ថ្នាក់ខេត្ត អាជ្ញាធរមូលដ្ឋាន ដៃគូអភិវឌ្ឍន៍ និងបុគ្គលិកសុខាភិបាលគ្រប់ថ្នាក់ និងអ្នកស្ម័គ្រចិត្តតាមភូមិ។

**ជំហានទី២** សម្រាប់១៥ខេត្ត គឺខេត្តកំពត ព្រះសីហនុ កោះកុង កំពង់ស្ពឺ ពោធិសាត់ ប៉ៃលិន បាត់ដំបង បន្ទាយមានជ័យ ឧត្តរមានជ័យ សៀមរាប ព្រះវិហារ រតនគិរី មណ្ឌលគិរី តាកែវ និងខេត្តក្រចេះ។ ក្នុងជំហ៊ានទី២ នេះមុងចំនួន ១.៩ លាន ( មួយលាន ប្រាំបួនសែន) នឹងត្រូវប្រគល់ជូនដោយឥតបង់ថ្លៃដល់ដៃប្រជាជនជាង ៦២៨ពាន់គ្រួសារ ( ជាង ២លាននាក់) ក្នុង ៣០១៤ភូមិ ( បីពាន់ ដប់បួន) ដែលប្រឈមនឹងការចម្លងមេរោគគ្រុនចាញ់ ហើយការប្រគល់នេះត្រូវធ្វើឱ្យបានចប់នៅចុងខែកុម្ភៈនេះ។ គ្រួសារនីមួយៗត្រូវចូលរួមធ្វើសំរង់ស្ថិតិក្នុងសៀវភៅ១ក្បាល ( សៀវភៅ១ សំរាប់១ខ្នងផ្ទះ) ហើយការធ្វើសំរង់ស្ថិតិនេះទៀតសោតក៏មិនមានការយកកំរៃ ឬទទួលអំណោយពីប្រជាជនដែរ។ ពេលប្រគល់/ទទួលមុងត្រូវមានផ្តិតមេដៃរបស់អ្នកទទួល។ យុទ្ធនាការចែកមុងនេះ ត្រូវមានការបន្តសហការយ៉ាងជិតស្និទ្ធជាមួយក្រុមការងារពិសេសលុបបំបាត់ជំងឺគ្រុនចាញ់ខេត្ត ដែលសុទ្ធតែមានអភិបាលរងខេត្ត១ រូបជាប្រធាន និងមានសមាជិកមកពីផ្នែក/វិស័យពាក់ព័ន្ធចូលរួមផង។ មន្ទីរសុខាភិបាលដែលជាលេខាធិការដ្ឋានរបស់ក្រុមការងារនេះ ត្រូវទទួលខុសត្រូវដឹកនាំការធ្វើយុទ្ធនាការនេះនៅក្នុងខេត្តរៀងៗខ្លួន ដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ ជាពិសេស ត្រូវការពារជាមុននូវបាតុភាពអសកម្មដែលអាចកើតមាន ជាយថាហេតុ។

ក្នុងឱកាសដ៏មានតម្លៃនេះ ខ្ញុំសូមសម្តែងនូវការកោតសរសើរដល់មន្ត្រីសុខាភិបាលគ្រប់ថ្នាក់ ជាពិសេសមន្ត្រីរបស់កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ នឹងមន្ត្រីក្នុងកម្មវិធីចាក់ថ្នាំបង្ការគ្រប់ថ្នាក់ ដែលមានគំនិតច្នៃប្រឌិតផ្តួចផ្តើមរួមបញ្ចូលការប្រគល់មុងជូនមេគ្រួសារនៅភូមិបទផ្លា ជាមួយនឹងការផ្តល់បន្ថែមថ្នាំបង្ការបង្កើនអត្រាគ្របបណ្តប់គ្រប់មុខវ៉ាក់សាំង ដើម្បីឱ្យកុមារ និងស្ត្រីក្នុងតំបន់ងាយរងគ្រោះអាចទទួលថ្នាំបង្ការបានដូចគ្នានៅទូទាំងប្រទេស។ ការរួមបញ្ចូលនេះនាំឱ្យមាតាបិតា កុមារទារក ចំណេញពេលវេលាមកតែម្តងបានទទួលផលសេវាពីរប្រភេទជាមួយគ្នា។ ខ្ញុំសូមអំពាវនាវដល់មាតាបិតាទាំងអស់ សូមនាំកូនចៅមកទទួលថ្នាំបង្ការគ្រប់គ្នា និងគ្រប់ចំនួន និងសូមអំពាវនាវដល់ស្ត្រីមានផ្ទៃពោះទាំងអស់ និងស្ត្រីដែលនឹងក្លាយជាអនាគតមាតា សូមមកទទួលថ្នាំបង្ការជំងឺតេតាណូសឱ្យបានគ្រប់ៗគ្នា ហើយពេលត្រឡប់ទៅវិញត្រូវប្រើប្រាស់ថ្នាំដែលបានទទួលទាំងនេះឱ្យបានត្រឹមត្រូវទៀងទាត់កុំធ្វេសប្រហែស។ ជាមួយនឹងការខិតខំរបស់បុគ្គលិក និងមន្ត្រីទាំងអស់ និងការចូលរួមរបស់បងប្អូនទាំងអស់ ក្រសួងសុខាភិបាលមានជំនឿថា ប្រទេសកម្ពុជាប្រាកដជានឹងអាចបំបាត់ជំងឺគ្រុនចាញ់នៅឆ្នាំ ២០២៥ ហើយអាចបំបាត់ជំងឺកញ្ជ្រឹល-តេតាណូសមាតា និងទារក ក្នុងឆ្នាំ ២០១២ ជាមិនខាន ហើយបងប្អូន និងកូនចៅទាំងអស់នឹងមានសុខភាពល្អ ជៀសផុតភាពក្រីក្រ មានជីវភាពរស់នៅសម្បូរសប្បាយក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

ឆ្លៀតក្នុងឱកាសនេះខ្ញុំសូមថ្លែងអំណរគុណ និងកោតសរសើរចំពោះការខិតខំប្រឹងប្រែងរបស់មន្ត្រីសុខាភិបាលគ្រប់ជាន់ថ្នាក់ ស្ថាប័នជំនាញពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងដៃគូអភិវឌ្ឍន៍នានា ដែលបានជួយឧបត្ថម្ភគាំទ្រដល់វិស័យសុខាភិបាលកម្ពុជា ជាពិសេស នៅក្នុងខេត្តសៀមរាបនេះ ។

ជាទីបញ្ចប់ខ្ញុំសូមជូនពរដល់ ឯកឧត្តម លោក-លោកស្រី និងប្រជាពលរដ្ឋទាំងអស់ សូមបានប្រកបនូវពុទ្ធពរ៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ ព្រមទាំងទទួលបានជោគជ័យគ្រប់ភារកិច្ច ។

ខ្ញុំសូមប្រកាស **បើកយុទ្ធនាការចែកមុងជ្រលក់ថ្នាំទូទាំងប្រទេស ជំហ៊ានទី២ ចាប់ពីពេលនេះតទៅ ។**

**សូមអរគុណ**







